*រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៥*

# សេចក្តីសំរេចលេខ ០៥ សសរ
# ស្តីពីនិតិវិធីថ្មីក្នុងការនាំចេញឈើមូល ឈើអារ និង ឈើកែច្នៃទៅបរទេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញក្រឹត្យច្បាប់លេខ ៣៥ ក្រ.ច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- យោងតាមស្មារតីនៃអង្គប្រជុំអន្តរក្រសួងនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៤

## សំរេច

**ប្រការ ១ :** លុបនិតិវិធីនិងបែបបទនៃការនាំឈើចេញ ដែលមានចែងក្នុងសេចក្តីសំរេចលេខ ៦៥ សសរ ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៩៤ ។

**ប្រការ ២ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវកសាងផែនការនាំចេញឈើមូល ឈើអារ និងឈើកែច្នៃ ប្រចាំឆ្នាំ ។ គំរោងផែនការនេះ ត្រូវតាក់តែងឡើងដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ឈើដ៏មានប្រសិទ្ធភាព ស្ថិតស្ថេរយូរអង្វែង ធានានូវនយោបាយស្ថេរភាពបរិយាកម្មសេដ្ឋកិច្ចជាតិ នយោបាយគ្រប់គ្រងបរិដ្ឋាន និងត្រូវផ្តើមចេញពីកិច្ចព្រមព្រៀងផ្លាស់ប្តូរទំនិញ និង កិច្ចសន្យាវិនិយោគទុនបាន ព្រៃសម្បទាន ព្រៃគុប រោងចក្រអារឈើ រោងចក្រកែច្នៃឈើ និងគោលដៅផ្សេងៗ ។ កំរិតកំណត់ផែនការនេះត្រូវដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត ហើយគឺជាឧបសម្ព័ន្ធមួយនៃផែនការចំណូលចំណាយថវិការដ្ឋសំរាប់ឆ្នាំសារពើពន្ធនិមួយៗ ។

**ប្រការ ៣ :** ចំពោះករណីឈើមូល ឈើអារ និងឈើកែច្នៃក្រៅកំរិតកំណត់ផែនការ ត្រូវសុំការអនុញ្ញាតនាំចេញពីរាជរដ្ឋាភិបាល ។

**ប្រការ ៤ :** ចំពោះករណីឈើមូល ឈើអារ និងឈើកែច្នៃដែលធ្វើអាជីវកម្មខុសច្បាប់ដែលរដ្ឋកំណត់ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

**ប្រការ ៥:** រាល់ប្រាក់ចំណូលដែលបានពីការបង់ថ្លៃឈើឈរ ពន្ធនាំចេញ និងពីការលក់និងនាំចេញឈើប្លុល ឈើអារនិងឈើកែច្នៃ ឈើរីបអូស ព្រមទាំងកំរៃផ្សេងៗ ត្រូវបង់ចូលរតនាគារទាំងអស់ ។

**ប្រការ ៦:** អាជីវករ ឬអ្នកនាំចេញត្រូវយកប័ណ្ណចំណូលពីរតនាគារទៅបង្ហាញដល់នាយកដ្ឋានរុក្ខាប្រមាញ់ ទីចាត់ការគយ និង ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៧:** លើរាល់លិខិតស្នើសុំនាំចេញត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ នាយកដ្ឋានរុក្ខាប្រមាញ់មានភារកិច្ចចុះហត្ថលេខាលើអាជ្ញាប័ណ្ណនាំចេញ ក្នុងឋានៈជាអ្នកនាំចេញ ឬ ជាអ្នកជួយនាំចេញ ក្រោយពេលពិនិត្យឃើញមានឈើជាក់ស្តែងតាមសំណើ ទាំងខាងបរិមាណ ទាំងខាងគុណភាព ។

**ប្រការ ៨:** ក្រសួងពាណិជ្ជកម្មមានភារកិច្ចចេញអាជ្ញាប័ណ្ណនាំចេញឈើប្លុល ឈើអារនិងឈើច្នៃ ផ្តល់អោយអ្នកនាំចេញ និងចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម ( ...........................) ក្រោយពីបានឃើញនូវប័ណ្ណចំណូលពី រតនាគារឬពីធនាគារជាតិនិងសេចក្តីបញ្ជាក់ត្រួតពិនិត្យរបស់គយ ។

**ប្រការ ៩:** ទីចាត់ការគយ និងរដ្ឋាករ ត្រូវមានភារកិច្ចចុះត្រួតពិនិត្យនៅតាមមាត់ច្រកដែលត្រូវបានទទួលការអនុញ្ញាតឱ្យប្រគល់ ឈើប្លុល ឈើអារ និងឈើកែច្នៃនាំចេញ និងធ្វើការកត់ត្រាបញ្ជាក់លើខ្នងអាជ្ញាប័ណ្ណអំពីបរិមាណនិងគុណភាពឈើប្លុល ឈើអារ ឬឈើកែច្នៃដែលបានអនុវត្តនាំចេញរួចហើយ ផ្ញើជូនមកក្រសួងពាណិជ្ជកម្មមួយច្បាប់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទមួយច្បាប់ និងទីស្តីការគណៈរដ្ឋមន្ត្រីមួយច្បាប់ ដើម្បីតាមដានការអនុវត្តន៍ ។

**ប្រការ ១០** ចំពោះមាត់ច្រកដែលធ្វើការប្រគល់ឈើប្លុល ឬ ឈើអារ ឬ ឈើកែច្នៃនាំចេញ មាន :

_កំពង់ផែអន្តរជាតិក្រុងសីហនុ

_កំពង់ផែភ្នំពេញ

_មាត់ច្រកផ្សេងៗទៀតដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងស្តីពីការបើកមាត់ច្រក រវាងរដ្ឋាភិបាលទ្វេភាគី ឬ ពហុភាគី ។

_និងមាត់ច្រកនានាដែលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

នៅរាល់គ្រប់មាត់ច្រកដែលអនុញ្ញាតអោយនាំចេញត្រូវមានដាក់ទីតាំងបុស្តិ៍គយប្រចាំការ ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិក្រមសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

**ប្រការ ១១ :** ចំពោះការសុំនាំចេញឈើមូល ឬ ឈើអារ ឬ ឈើកែច្នៃឆ្លងកាត់(......... ) ប្រទេសជិតខាងណា ដែលមានកិច្ចព្រមព្រៀងទ្វេភាគី ត្រូវប្រើប្រាស់អាជ្ញាប័ណ្ណនាំចេញឆ្លងកាត់ដែលចេញដោយ ក្រសួងពាណិជ្ជកម្ម ។ ចំពោះប្រទេសណា ដែលពុំទាន់មានកិច្ចព្រមព្រៀងទំនិញឆ្លងកាត់ទ្វេភាគី នៅឡើយ អ្នកនាំចេញត្រូវធ្វើលិខិតស្នើទៅក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិតាម រយៈក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១២ :** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចធ្វើទំនាក់ទំនងជាមួយប្រទេស ណាដែល ត្រូវស្នើសុំ ការអនុញ្ញាតនិឆ្លងកាត់ ។

**ប្រការ ១៣ :** ក្រសួងស្ថាប័នដែលមានការទាក់ទងដល់ការអនុវត្តន៍សេចក្តីសំរេចនេះត្រូវយកចិត្តទុក ដាក់បំព្រួញ លំដាប់លំដោយ នៃការធ្វើបែបបទរដ្ឋបាលឱ្យបានខ្លីបំផុត សំដៅជំរុញការអនុវត្តន៍ឱ្យមាន ប្រសិទ្ធភាពល្អ ។

**ប្រការ ១៤ :** ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវ ចេញសេចក្តីប្រកាសស្តីពីទំរង់បែបបទសុំនាំចេញឈើ តំរូវកិច្ចសន្យាលក់នាំចេញ បរិមាណនិង គុណភាពនាំចេញ អត្រាពន្ធ និង កំរៃផ្សេងៗដែលត្រូវបង់ជូនរដ្ឋ និង កំណត់និយមន័យឈើកែច្នៃឱ្យ បានច្បាស់លាស់ ។ ចំពោះតំលៃនាំចេញត្រូវកំណត់ទៅតាមថ្លៃទីផ្សារអន្តរជាតិដែលអន្តរក្រសួង កំណត់ ។

**ប្រការ ១៥ :** ក្នុងដំណាក់កាលដោះស្រាយបញ្ហាសេសសល់កន្លងមក ចំពោះអាជីវករដែលបានគោលការណ៍ អនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យនាំចេញរួចហើយ តែពុំទាន់បានអនុវត្តត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាម ទំរង់បែបបទនិតិវិធីថ្មីនេះ ។

**ប្រការ ១៦ :** ចំពោះសំណើថ្មីស្តីពីការសុំនាំចេញឈើមូល ឈើអារនិងឈើកែច្នៃ អាចប្រព្រឹត្តទៅបានលុះត្រាតែ បានបញ្ចូលក្នុង កំរិតកំណត់ផែនការរដ្ឋ និង ក្រោយពីមានសេចក្តីប្រកាសអន្តរក្រសួងស្តីពីទំរង់បែប បទសុំនាំចេញឈើមូល ឈើអារ និង ឈើកែច្នៃ ដូចដែលបានកំណត់ក្នុងប្រការទី ១៤ នៃសេចក្តី សំរេចនេះ ។

**ប្រការ ១៧ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះ ហត្ថលេខានេះតទៅ ។

**ប្រការ ១៨** : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)